**សុន្ទរកថាបើកកម្មវិធី**

**ដោយ**

**លោកជំទាវ ប្រធានគណៈកម្មការទី ៩ នៃរដ្ឋសភាជាតិ**

**ក្នុងកិច្ចពិភាក្សាតុមូល**

**ស្តីពី**

**" ស្ថានភាពជាក់ស្តែងនៃឧស្សាហកម្មកាត់ដេរកម្ពុជាបន្ទាប់ពីបញ្ចប់ប្រព័ន្ធកូតា "**

**(ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង ១២:០០ ដល់ម៉ោង ១៨:០០)**

**នៅសណ្ឋាគារ HIMAWARI**

**ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អ្នកនាងកញ្ញា ទាំងអស់ជាទីគោរព!**

ថ្ងៃនេះ ខ្ញុំម្ចាស់ នាងខ្ញុំ មានកិត្តិយស និង សេចក្តីរីករាយជាខ្លាំង ដោយបានចូលរួមក្នុងកិច្ចពិភាក្សាតុមូល ស្តីពី "**ស្ថានភាពជាក់ស្តែងនៃឧស្សាហកម្មកាត់ដេរកម្ពុជាបន្ទាប់ពីបញ្ចប់ប្រព័ន្ធកូតា**" ដែលរៀបចំឡើងដោយ **វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា** (EIC) ក្រោមការឧបត្ថម្ភ និង គាំទ្រពី **គម្រោងគាំទ្រនីតិបញ្ញត្តិកម្ពុជា-កាណាដា** (CCLSP) ។

ជាបឋម ខ្ញុំសូមកោតសរសើរដោយស្មោះ និង អរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក **សុក ហាច នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា** (EIC) និង **លោក ម៉ែន ប៊ុនឡេង នាយកគម្រោងគាំទ្រនីតិបញ្ញត្តិកម្ពុជា-កាណាដា** (CCLSP) ដែលបានរៀបចំនូវកិច្ចពិភាក្សាពិគ្រោះយោបល់ ដ៏មានសារៈសំខាន់នេះឡើង ។

ជាក់ស្តែងនៅកម្ពុជា វិស័យឧស្សាហកម្មកាត់ដេរបានដើរតួនាទីយ៉ាងសំខាន់ សំរាប់នាំចេញផលិតផលទៅប្រកួតប្រជែងលើទីផ្សារអន្តរជាតិ និង ជាផ្នែកមួយយ៉ាងសំខាន់នៃកំណើនសេដ្ឋកិច្ច ក៏ដូចជាការចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ បន្ទាប់ពីកម្ពុជាបានចុះកិច្ចព្រមព្រៀងវាយនភ័ណ្ឌពហុសរសៃរអំបោះ MFA ការកំណត់បរិមាណ (កូតា) ត្រូវបានដាក់កំហិតដោយរដ្ឋាភិបាលនៃប្រទេសអភិវឌ្ឍន៏មួយចំនួន។ តាមរយៈកិច្ចព្រមព្រៀងនេះ បណ្តាលអោយមានក្រុមហ៊ុនកាត់ដេរធំៗ បានប្តូរអាជីវកម្មរបស់ខ្លួនមួយចំនួនមកបណ្តាក់ទុនរួមជាមួយ នឹងតម្លៃពលកម្មទាបដែលជំរុញអោយឧស្សាហកម្មកាត់ដេរកម្ពុជា ១៩៩៤ ទៅឆ្នាំ ២០០៦ មានការកើនឡើង

គួរអោយ ហើយផលិតផលកាត់ដេរស្ទើរតែទាំងអស់នេះត្រូវបាន នាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង សហគមអ៊ឺរ៉ុប (EU)។ ឧស្សាហកម្មកាត់ដេរនេះ បានផ្តល់ការងារជាច្រើន ដល់ប្រជាពលរដ្ឋប្រមាណជាង ២៨ ម៉ឺននាក់ភាគច្រើន គឺប្រជាពលរដ្ឋដែលក្រីក្ររស់នៅតាមបណ្តាខេត្ត និង តាមជនបទនានា ដែលពួកគាត់អាចរកបានចំណូលបានពី ៣០ ដុល្លា ទៅ ៨០ ដុល្លាក្នុងមួយខែ។ គ្រួសារដែលមានកូនស្រី ជាគ្រួសារដែលមានសំណាង ពីព្រោះពួកគាត់អាចរកប្រាក់បានមួយចំនួន ពីពលកម្មរបស់កូនគាត់ដែលបានធ្វើការក្នុងវិស័យកាត់ដេរ។ ប្រមាណពី ៧០% ទៅ ៨០% នៃយុវនាតីដែលមានអាយុពី ១៦ ឆ្នាំ ដល់ច្រើនជាង ២០ ឆ្នាំបានទៅក្រុងភ្នំពេញ ឬ តំបន់ទីក្រុងផ្សេងទៀត ដើម្បីធ្វើការជាកម្មការិនីរោងចក្រកាត់ដេរ។ ពួកគេអាចសម្រាលបន្ទុកមួយចំនួនក្នុងគ្រួសារ ដោយឪពុកម្តាយពួកគេឈប់ព្រួយបារម្ភពីបញ្ហាចំណាយ និង ហើយនឹងទទួលបានប្រាក់បញ្ញើថែមទៀតពួកគេ ដែលមានជាមធ្យមចំនួន ៣០ ដុល្លារ ក្នុងមួយខែផងដែរ ។ បើតាមឯកសារវាយតំលៃភាពក្រីក្រឆ្នាំ ២០០៦ របស់ធានាគារពិភពលោក ឧស្សាហកម្មកាត់ដេរមានសក្តានុពលលើកកំពស់ប្រាក់ចំណូលរហូតដល់ ៩ភាគរយ នៃគ្រួសារទាំងអស់។ ដូច្នេះវិស័យកាត់ដេរមានតួនាទីសំខាន់ណាស់នៅក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

នៅចុងឆ្នាំ ២០០៤ កិច្ចព្រមព្រៀងវាយនភ័ណ្ឌពហុសសៃអំបោះត្រូវបានបញ្ចប់ ប្រទេសកម្ពុជាត្រូវប្រឈមមុខនៅការប្រកួតប្រជែងខ្លាំងក្លា ជាមួយនឹងបណ្តាប្រទេសផ្សេងៗទៀតនៅលើពិភពលោក ជាពិសេសប្រទេសចិនដែលជាគូរប្រកួតប្រជែងដ៏សំខានមួយ។ ជាមួយគ្នានេះ រដ្ឋាភិបាលក៏មានការខិតខំប្រឹងប្រែងលើកស្ទួយវិស័យនេះផងដែរ ដូចជាការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ការធ្វើកំណែទម្រង់ពាណិជ្ជសំខាន់ៗមួយចំនួន រួមនឹងការកាត់បន្ថយការិយាធិបតី និងជាពិសេសការអនុវត្តគម្រោងអំពីការគោរពច្បាប់ការងារដែលត្រួតពិនិត្យដោយអង្គការពលកម្មអន្តរជាតិ (ILO) ដើម្បីធានានូវការបញ្ជាទិញពីអតិថិជននៅឯសហរដ្ឋអាមេរិកជាដើម។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកំពុងតែព្យាយាមបញ្ចុះបញ្ចូលសភាសហរដ្ឋអាមេរិកឱ្យអនុម័តច្បាប់ពាណិជ្ជកម្មមួយ ដែលតាមរយៈច្បាប់នេះ ប្រទេសកម្ពុជាអាចនឹងទទួលបាននូវការនាំចេញនូវទំនិញទៅសហរដ្ឋអាមេរិកដោយគ្មានការបង់ពន្ធឡើយ ។

ដោយឡែករដ្ឋសភា ក៏ដូចជាគណកម្មការជំនាញ បានបំពេញតួនាទីរបស់ខ្លួនក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ដែលរាជរដ្ឋាភិបាលបានបញ្ជូនមកព្រមទាំងពិនិត្យពិភាក្សា និង អនុម័តច្បាប់មួយចំនួនបន្ថែមទៀត ដើម្បីឆ្លើយតបទៅនិងលក្ខខណ្ឌ នៃការចូលជាសមាជិករបស់អង្គការពិភពលោក ៩ឡឹជ ដែលតម្រូវអោយកម្ពុជាមានច្បាប់គ្រាប់គ្រាន់។ ម្យ៉ាងទៀត ដើម្បីឆ្លើយតបទៅនិងបំណងប្រាថ្នា និង តម្រូវការរបស់ពាណិជ្ជករខ្មែរទូទៅទាំងក្នុង និង ក្រៅប្រទេស ដែលក្នុងនោះមានទាំងវិនិយោគិនបរទេសផង ដេម្បីជំរុញដល់ដំណើរការអភិវឌ្ឍន៍សង្គមរបស់ខ្លួនស្របតាមទិសដៅទីផ្សារសេរី ដែលជាឧបករណ៍ដ៏មានឥទ្ធិពល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បង្កើនការការងារដល់ប្រជាពលរដ្ឋធ្វើ។ លើសពីនេះ ទៀត គណកម្មការជំនាញតាមដានសកម្មភាព

នៃការអនុវត្តច្បាប់របស់ក្រសួងពាក់ព័ន្ធ ដើម្បីជំរុញយន្តការអនុវត្តច្បាប់អោយមានប្រសិទ្ធភាព ដើម្បីជំរុញអោយការអភិវឌ្ឍន៏ប្រទេសកាន់តែមានសន្ទុះលឿនទៅមុខ។

ដូច្នេះសំណួរដ៏មានសារៈសំខាន់សំរាប់កិច្ចពិភាក្សាតុមូលនាពេលនេះគឺ:

១-តើស្ថានភាពនៃវិស័យឧស្សាហកម្មកាត់ដេរ (ទាំងរោងចក្រ ក៏ដូចជាកម្មកររោងចក្រ) មានស្ថានភាព ដូចម្តេចដែរ នៅក្នុងឆ្នាំ ២០០៥ កន្លងទៅនេះ ?

២-តើអ្វីទៅជាទស្សនៈវិស័យរបស់វិស័យឧស្សាហកម្មកាត់ដេរកម្ពុជានៅឆ្នាំ ២០០៦ និង តទៅថ្ងៃអនាគត ?

៣-តើមានប្រភពកំណើនណាខ្លះផ្សេងទៀត (ក្រៅពីវិស័យកាត់ដេរ) សំរាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចិរភាព ?

## ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អ្នកនាងកញ្ញា,

វេទិការពិភាក្សានាពេលនេះគឺ បានផ្តល់នូវឱកាសដ៏ប្រពៃ និង ការជួបជុំនៃថ្នាក់ដឹកនាំគ្រប់និន្នាការនយោបាយ ដើម្បីជជែកផ្លាស់ប្តូរយោបល់ស្វែងរកគំនិត និង អនុសាសន៏ល្អៗ ពិសេសគឺដើម្បីជំរុញអភិវឌ្ឍន៏ ឧស្សាហកម្មកម្ពុជា ដើម្បីអាចប្រកួតប្រជែងលើឆាកអន្តរជាតិ។

ជាទីបញ្ចប់ នាងខ្ញុំ សូមគោរពថ្វាយព្រះពរ និង ជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អ្នកនាងកញ្ញា អោយជួបប្រទះតែនឹងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀតឃ្លាតឡើយ ។ សូមជូនពរ អង្គកិច្ចពិភាក្សាតុមូលដ៏មានសារៈសំខាន់នាថ្ងៃនេះ ទទួលបានជោគជ័យ។

ក្នុងនាមអង្គសន្និបាត និង អង្គកិច្ចពិភាក្សា ខ្ញុំម្ចាស់ នាងខ្ញុំ សូមប្រកាសបើកជាផ្លូវការ ចាប់ពីពេលនេះតទៅ ។

**សូមអរព្រះគុណ និងអរគុណ!**